ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល
THE ARBITRATION COUNCIL

**លេខ និង ឈ្មោះសំណុំរឿង : ១១៤/១០-ប៊ី រី អ៊ីកែរីល**

**កាលបរិច្ឆេទនៃសេចក្តីបង្គាប់ : ថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០១០**

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា៣១៣នៃច្បាប់ស្តីពីការងារ)

**សមាសភាពក្រុមអាជ្ញាកណ្តាល**

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក: **ម៉ារ សំបូរណា**

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត: **អាន វីរៈ**

ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ: **ប៉ែន ប៊ុនឈា**

**ភាគីនៃវិវាទ**

១- ភាគីនិយោជក

ឈ្មោះ : **ក្រុមហ៊ុន ប៊ី រី អ៊ីកែរីល (ខេមបូឌា)**

អាសយដ្ឋាន : ភូមិជម្ពូវ័ន្ត សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ

ទូរស័ព្ទ : ០១២ ៨៨២ ៨៦៨ ទូរសារ : គ្មាន

តំណាងភាគីនិយោជក :

១- លោក យ័ព្យ ចណ្ណារ៉ា រដ្ឋបាល

២- លោកស្រី ឈុន សម្ផស្ស រដ្ឋបាល

២- ភាគីកម្មករនិយោជិត

ឈ្មោះ : **-សម្ព័ន្ធសហជីពចលនាកម្មករ**

**-សហជីពចលនាកម្មករ ប្រចាំរោងចក្រ ប៊ី រី**

អាសយដ្ឋាន : ភូមិជម្ពូវ័ន្ត សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ

ទូរស័ព្ទ : ០១២ ៩២៩ ១៧៤ ទូរសារ : គ្មាន



ផ្ទះលេខ ៧២ ផ្លូវលេខ ៥៩២ (កែងផ្លូវលេខ ៣២៧) សង្កាត់បឹងកក់ ២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។ ទូរស័ព្ទ/ទូរសារ: ៨៥៥-២៣ ៨៨១ ៨២៤
No. 72, Street 592 (corner of St. 327), Sangkat Boeung Kak II, Khan Tuol Kork, Phnom Penh ◈ Tel/Fax: 855-23 881 824
E-mail: secretariat@arbitrationcouncil.org ◈ Website: www.arbitrationcouncil.org

តំណាងកម្មករនិយោជិតៈ

| | | |
|---|---|---|
| ១- | លោក ហ្វា សាលី | អគ្គលេខាធិការសម្ព័ន្ធសហជីពចលនាកម្មករ |
| ២- | លោក ខាត់ ឡូត | មន្ត្រីសម្ព័ន្ធសហជីពចលនាកម្មករ |
| ៣- | កញ្ញា ឡើ សាម៉េត | ប្រធានសហជីពចលនាកម្មករប្រចាំរោងចក្រ ប៊ី រី |
| ៤- | កញ្ញា សឿន សុផល្លា | អនុប្រធានសហជីព |
| ៥- | កញ្ញា សឿន ស្រីមុំ | លេខាធិការសហជីព |

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

១- កម្មករនិយោជិតនៅតែទាមទារឱ្យក្រុមហ៊ុនរក្សាប្រាក់ឈ្នួល និងប្រាក់រង្វាន់នៅដដែល នៅពេលរថយន្តខូចតាមផ្លូវ ។ ដោយឡែកភាគីក្រុមហ៊ុនបញ្ជាក់ថា ក្រុមហ៊ុនទុកឱកាសឱ្យមួយម៉ោងពេលរថយន្តខូច និងពីរម៉ោងក្នុងមួយខែ ដោយរក្សាប្រាក់ឈ្នួល និងប្រាក់រង្វាន់នៅដដែល ។

២- កម្មករនិយោជិតនៅតែទាមទារឱ្យក្រុមហ៊ុនបើកប្រាក់ឈ្នួល និងប្រាក់បន្ទាប់បន្សំប្រចាំខែកញ្ញា នៅថ្ងៃទី០៤ ខែតុលា ឆ្នាំ២០១០។ ដោយឡែកភាគីនិយោជកបញ្ជាក់ថា ក្រុមហ៊ុនបើកប្រាក់ឈ្នួល និងប្រាក់បន្ទាប់បន្សំប្រចាំខែកញ្ញា នៅថ្ងៃទី០៥ ខែតុលា ឆ្នាំ២០១០ ។

៣- កម្មករនិយោជិតនៅតែទាមទារឱ្យក្រុមហ៊ុនអនុញ្ញាតឱ្យកម្មករឈប់សម្រាកមានជំងឺ ដោយអនុវត្តយកសំបុត្រពេទ្យ ឬពេទ្យឯកជនធំៗ ដោយរក្សាប្រាក់ឈ្នួល និងប្រាក់រង្វាន់នៅដដែល។ ដោយឡែកភាគីនិយោជកបញ្ជាក់ថា ក្រុមហ៊ុនទទួលយកតែសំបុត្រពេទ្យរដ្ឋ ឬពេទ្យបង្អែក ដោយរក្សាប្រាក់ឈ្នួល និងប្រាក់រង្វាន់ ដោយកាត់សមាមាត្រតាមចំនួនថ្ងៃដែលបានឈប់ ។

៤- កម្មករនិយោជិតនៅតែទាមទារឱ្យក្រុមហ៊ុនចេញក្រដាសបើកប្រាក់ឈ្នួល ឱ្យបានមើលមុនថ្ងៃបើកប្រាក់ឈ្នួលប្រចាំខែ ។ ដោយឡែកភាគីនិយោជកបញ្ជាក់ថា ចំពោះក្រដាសបើកប្រាក់ឈ្នួល ក្រុមហ៊ុននឹងផ្តល់ឱ្យនៅពេលបើកប្រាក់ឈ្នួលប្រចាំខែតែម្តង ។

៥- កម្មករនិយោជិតនៅតែទាមទារឱ្យក្រុមហ៊ុនបើកប្រាក់ថ្លៃបាយក្នុងមួយសប្តាហ៍ម្តង។ ដោយឡែកភាគីនិយោជកបញ្ជាក់ថា ចំពោះលុយថ្លៃបាយ ក្រុមហ៊ុនបើកឱ្យជាមួយប្រាក់ឈ្នួលប្រចាំខែដែរ ។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ (ខ)(មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ០៩៩ សកបយ ចុះថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជា

THE ARBITRATION COUNCIL

ឧបសម្ព័ន្ធនៃប្រកាស លេខ ០៩៩ សកបយ ចុះថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ១៣៣ កប/ប្រក ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១០ (អាណត្តិទី៥)។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី ២ (ក) នៃច្បាប់ស្តីពីការងារ។ ប៉ុន្តែការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការមិនសះជាលេខ ៩៦៦ ក.ប/អក/វ.ក ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១០ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១០។

## សវនាការ និង សង្ខេបនីតិវិធី

**ទីកន្លែងសវនាការ :** ក្រុមប្រឹក្សាអាជ្ញាកណ្តាល "ភូមិគ្រឹះលេខ ៧២ ផ្លូវលេខ ៩៩២ កាច់ជ្រុងផ្លូវលេខ ៣២៧ (ទល់មុខវិទ្យាល័យឥន្ទ្រទេវី) សង្កាត់បឹងកក់២ ខណ្ឌទួលគោក រាជធានីភ្នំពេញ។

**កាលបរិច្ឆេទសវនាការ :** ថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ២០១០ (វេលាម៉ោង ១៤:00 នាទី រសៀល)

**បញ្ហានៃនីតិវិធី :**

នៅថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១០ នាយកដ្ឋានវិវាទការងារ បានទទួលពាក្យបណ្តឹងរបស់ក្រុមហ៊ុន ប៊ី រី អឹកែរីល លេខ BR ០៩/១០ ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១០ ស្តីពីការទាមទាររបស់កម្មករនិយោជិតសុំឱ្យក្រុមហ៊ុនកែលំអលក្ខខណ្ឌការងារឱ្យបានល្អប្រសើរ។

បន្ទាប់ពីបានទទួលពាក្យបណ្តឹងនេះមក នាយកដ្ឋានវិវាទការងារ បានចាត់តាំងមន្ត្រីជំនាញចុះទៅធ្វើការដោះស្រាយវិវាទការងារដល់ទីតាំងក្រុមហ៊ុន នៅថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១០ ដោយទទួលលទ្ធផលមិនសះជានឹងគ្នាចំនួន ០៥ ចំណុច លើការទាមទារចំនួន ១១ ចំណុច។ ចំណុចវិវាទដែលមិនសះជានឹងគ្នាចំនួន ០៥ ចំណុចនេះ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១០ តាមរបាយការណ៍ដោះស្រាយវិវាទការងាររួមមិនសះជាលេខ ៩៦៦ កប/អក/វក ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១០។

បន្ទាប់ពីបានទទួលសំណុំរឿងនេះរួចមក លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល បានធ្វើការកោះអញ្ជើញភាគីនិយោជក និងភាគីកម្មករនិយោជិត មកសវនាការ និងធ្វើការផ្សះផ្សាលើករណីមិនសះជាចំនួន ០៥ ចំណុចនេះ នៅថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១០ វេលាម៉ោង ១៤:00 នាទី រសៀល។

ភាគីទាំងពីរមានវត្តមាននៅថ្ងៃសវនាការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានព្យាយាមសួររកនូវព័ត៌មានផ្សេងៗ ដែលទាក់ទងទៅនឹងវិវាទនេះ និងបានធ្វើការផ្សះផ្សាលើចំណុចវិវាទមិនសះជាចំនួន ០៥ ចំណុចនេះ បន្ថែមទៀត ហើយជាលទ្ធផល ភាគីកម្មករនិយោជិត និងនិយោជក បានធ្វើការព្រមព្រៀងគ្នាលើចំណុចវិវាទទី៣ ។ ចំណែកឯចំណុចវិវាទទី២ និងទី៤ ត្រូវបានភាគីកម្មករនិយោជិត យល់ព្រមដកចេញពីការទាមទារ។ ដូចនេះ ចំណុចវិវាទដែលនៅសល់មានចំនួន ២ ចំណុច ប៉ុណ្ណោះ គឺចំណុចវិវាទទី១ និងទី៥ ក្រុមប្រឹក្សា

អាជ្ញាកណ្ដាលធ្វើការពិចារណា និងដោះស្រាយ ដោយផ្អែកលើភស្តុតាង និងការរកឃើញនៃអង្គហេតុ ដូចខាងក្រោម៖

**ភស្តុតាង**

**សាក្សី និង អ្នកជំនាញក្រៅពីភាគី ៖ គ្មាន**

**ឯកសារ ទស្តុតាង ដែលក្រុមអាជ្ញាកណ្ដាលយកមកពិចារណាមាន**

**ក- ឯកសារបានទទួលពីភាគីនិយោជក ៖**

១- លិខិតផ្ទេរសិទ្ធិរបស់ប្រធានរដ្ឋបាលក្រុមហ៊ុន ប៊ី រី ជូនលោក យ័ព្យ ចណ្ណារ៉ា និងលោកស្រី ឈុន សម្ផស្ស ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១០ ។

២- សារណាសង្ខេបនៃវិវាទការងារនៅក្រុមហ៊ុន ប៊ី រី ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០១០ ។

៣- វិញ្ញាបនប័ត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មក្រុមហ៊ុន ប៊ី រី លេខ ៦១៩៦ ពណ.ចបព ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០០៨ ។

៤- លក្ខន្តិកៈក្រុមហ៊ុន ប៊ី រី ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០០៩ ។

៥- បទបញ្ជាផ្ទៃក្នុងក្រុមហ៊ុន ប៊ី រី ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០០៥ ។

៦- សេចក្ដីជូនដំណឹងក្រុមហ៊ុន ប៊ី រី លេខ BR 11/08 ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០០៨ ។

៧- លិខិតស្នើសុំឈប់មុនបុណ្យភ្ជុំបិណ្ឌ របស់កម្មករនិយោជិតក្រុមហ៊ុន ប៊ី រី ចុះថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០១០ ។

៨- សេចក្ដីជូនដំណឹងរបស់ក្រុមហ៊ុន ប៊ី រី ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១០ ។

៩- បញ្ជីឈ្មោះកម្មករក្រុម $A_2$ សុំច្បាប់នៅថ្ងៃទី១១ ខែតុលា ឆ្នាំ២០១០ ។

១០- បញ្ជីឈ្មោះកម្មករក្រុម $D_{55}$ សុំច្បាប់នៅថ្ងៃទី១១ ខែតុលា ឆ្នាំ២០១០ ។

១១- បញ្ជីឈ្មោះកម្មករក្រុមបត់ A សុំច្បាប់នៅថ្ងៃទី១១ ខែតុលា ឆ្នាំ២០១០ ។

១២- បញ្ជីឈ្មោះកម្មករក្រុម $LM_{31}$ សុំច្បាប់នៅថ្ងៃទី១១ ខែតុលា ឆ្នាំ២០១០ ។

១៣- ទំរង់បែបបទសុំច្បាប់របស់ឈ្មោះ ឡេង ខេម ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១០ ។

១៤- ទំរង់បែបបទសុំច្បាប់របស់ឈ្មោះ ឡាត់ ចាន់ ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១០ ។

១៥- ទំរង់បែបបទសុំច្បាប់របស់ឈ្មោះ អ៊ិត អូន ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១០ ។

១៦- ទំរង់បែបបទសុំច្បាប់របស់ឈ្មោះ ប៊ុត ស៊ីនឿន ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១០ ។

១៧- ទំរង់បែបបទសុំច្បាប់របស់ឈ្មោះ ម៉ែន ឡា ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១០ ។

១៨- បញ្ជីឈ្មោះកម្មករក្រុម $A_{18}$ សុំច្បាប់នៅថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១០ ។

THE ARBITRATION COUNCIL

១៩- បញ្ជីឈ្មោះកម្មករក្រុម $A_{23}$ សុំច្បាប់នៅថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១០ ។

២០- បញ្ជីឈ្មោះកម្មករក្រុម $LMB_3$ សុំច្បាប់នៅថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១០ ។

២១- បញ្ជីឈ្មោះកម្មករក្រុម $A_{42}$ សុំច្បាប់នៅថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១០ ។

២២- បញ្ជីឈ្មោះកម្មករក្រុម $A_{01}$ សុំច្បាប់នៅថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១០ ។

២៣- ទំរង់បែបបទសុំច្បាប់របស់ឈ្មោះ ផា សំអាត ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១០ ។

២៤- ប័ណ្ណពិនិត្យជំងឺរបស់ឈ្មោះ ផា សំអាត ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១០ ។

២៥- ទំរង់បែបបទសុំច្បាប់របស់ឈ្មោះ កង សុភន្ទី ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១០ ។

២៦- ប័ណ្ណពិនិត្យជំងឺរបស់ឈ្មោះ កង សុភន្ទី ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១០ ។

២៧- ទំរង់បែបបទសុំច្បាប់របស់ឈ្មោះ ម៉ា ផល្លី ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១០ ។

២៨- លិខិតបញ្ជាក់សុខភាពរបស់មន្ទីរសុខាភិបាលខេត្តកណ្តាលរបស់ឈ្មោះ អ៊ុយ ម៉ៅ ចុះថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០១០ ។

២៩- ទំរង់បែបបទសុំច្បាប់របស់ឈ្មោះ ញិល ស្រស់ ចុះថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០១០ ។

៣០- លិខិតបញ្ជាក់សុខភាពរបស់មន្ទីរសំរាកព្យាបាល និងសម្ភព ឡាំ ប៊ុនថន របស់ឈ្មោះ ញិល ស្រស់ ចុះថ្ងៃទី០៨ ខែ កញ្ញា ឆ្នាំ២០១០ ។

៣១- ទំរង់បែបបទសុំច្បាប់របស់ឈ្មោះ ស្រី នីន ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១០ ។

៣២- លិខិតបញ្ជាក់ឆ្លុះអេកូរបស់វេជ្ជ. ទូច ស៊ីម លើឈ្មោះ ស្រី នីន ។

៣៣- ទំរង់បែបបទសុំច្បាប់របស់ឈ្មោះ ខាំ រ៉ា ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១០ ។

៣៤- ព្រឹត្តិប័ត្រវិភាគសុខភាពរបស់បន្ទប់ពិសោធន៍វេជ្ជសាស្ត្រ មូលមិត្ត របស់ឈ្មោះ ខាំ រ៉ា ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១០ ។

៣៥- លិខិតបញ្ជាក់សុខភាពរបស់មណ្ឌលសុខភាពត្រាំខ្នារ របស់ឈ្មោះ ខាំ រ៉ា ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ ២០១០ ។

៣៦- ទំរង់បែបបទសុំច្បាប់របស់ឈ្មោះ ដឹម សុខគា ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១០ ។

៣៧- លិខិតបញ្ជាក់សុខភាពរបស់មណ្ឌលសុខភាពបឹងខ្យាង ស្រុកប្រតិបត្តិតាខ្មៅ ខេត្តកណ្តាល របស់ឈ្មោះ ដឹម សុធា ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១០ ។

**ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត : គ្មាន**

**គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន ប៊ី វី លេខ ៩៦៦ ក.ប/អក/វ.ក ចុះថ្ងៃ ទី១៤ ខែតុលា ឆ្នាំ២០១០។

THE ARBITRATION COUNCIL

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមនៅក្រុមហ៊ុន ប៊ី វី ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១០

**ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល**

១- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការលេខ ៦១៥ កប/អក/វក/លកអ. ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១០។

២- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការលេខ ៦១៦ កប/អក/វក/លកអ. ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១០។

**អង្គហេតុ**

- ក្រោយពីបានពិនិត្យរបាយការណ៍នៃការផ្សះផ្សាវិវាទការងាររួម
- ក្រោយពីបានស្តាប់អំណះអំណាងរបស់តំណាងភាគីកម្មករនិយោជិត និង ភាគីនិយោជក
- ក្រោយពីបានពិនិត្យឯកសារបន្ថែម

**ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា :**

- ក្រុមហ៊ុន ប៊ី វី អីភែរីល បានចាប់ផ្តើមដំណើរការនៅក្នុងឆ្នាំ២០០៥ ហើយបច្ចុប្បន្ននេះ មានជួលកម្មករនិយោជិតសរុបចំនួន ២៩០០ នាក់ ។
- នៅក្នុងក្រុមហ៊ុននេះ មានសហជីពចំនួន ៥ ដែលមានដូចជា សហជីពខ្មែរ សហជីពសេរីកម្មករ សហជីពយុវជនខ្មែរ សហជីពចលនាកម្មករ និងសហជីពសិទ្ធិប្រយោជន៍កម្មករ។
- សហជីពចលនាកម្មករ គឺជាដើមបណ្តឹងនៅក្នុងសំណុំរឿងនេះ។ សហជីពនេះមានសមាជិកចំនួន ២០៨ នាក់។ ប៉ុន្តែ សហជីពបានទទួលស្គាល់ថា ចំនួនសមាកជិកដែលនិយោជកបានកាត់ប្រាក់ភាគទាន គឺមានចំនួនតែ ៨៨ នាក់ ទេ។

**ចំណុចវិវាទទី១: កម្មករនិយោជិតនៅតែទាមទារឱ្យក្រុមហ៊ុនរក្សាប្រាក់ឈ្នួល និងប្រាក់រង្វាន់ដដែល នៅពេលរថយន្តខូចតាមផ្លូវ**

- នៅក្នុងសវនាការ ភាគីកម្មករនិយោជិត បានដកចំណុចទាមទារទៅលើការសុំរក្សាប្រាក់ឈ្នួល ប៉ុន្តែរក្សាការទាមទារដោយសុំកុំឱ្យនិយោជកកាត់ប្រាក់រង្វាន់ការងារទៀងទាត់ទាំងអស់ នៅពេលដែលពួកគាត់មិនបានមកធ្វើការដោយសារតែរថយន្តដែលដឹកជញ្ជូនពួកគាត់មកធ្វើការខូចនៅតាមផ្លូវ។ ក្នុងការទាមទារនេះ ភាគីកម្មករនិយោជិតបានលើកឡើងថា នៅពេលដែលរថយន្តខូចម្តងៗ ម្ចាស់រថយន្តត្រូវចំណាយពេលយូរ ដើម្បីជួសជុលរថយន្ត។ កម្មករនិយោជិតបានបញ្ជាក់ថា ពុំមានរថយន្តដទៃមកទទួល

THE ARBITRATION COUNCIL

ពួកគាត់ទៅធ្វើការទេ ហើយពួកគាត់នឹងត្រូវចំណាយលុយច្រើននៅក្នុងការប្រើមធ្យោបាយធ្វើដំណើរផ្សេងទៀត ដើម្បីមកធ្វើការ ។

- ភាគីនិយោជកបានលើកឡើងថា និយោជកពុំអាចផ្តល់ជូនតាមការទាមទារបានទេ ដោយសារភាគីកម្មករនិយោជិត និងនិយោជកមានកិច្ចសន្យាទាក់ទងទៅនឹងពេលវេលាម៉ោងធ្វើការរួចហើយ ដែលស្របនឹងបទបញ្ជាផ្ទៃក្នុង ប្រការ ៣ ចែងថា កម្មករនិយោជិតត្រូវធ្វើការរយៈពេល ៨ ម៉ោងក្នុង១ថ្ងៃ ហើយចាប់ពីម៉ោង ៧:០០ នាទីព្រឹក ដល់ម៉ោង ១១:០០ នាទីថ្ងៃត្រង់ និងពេលរសៀល ចាប់ផ្តើមពីម៉ោង ១២:០០ នាទី ដល់ម៉ោង ៤:០០ នាទី ល្ងាច។ ដូចនេះ កម្មករនិយោជិតត្រូវគោរពពេលវេលានៃម៉ោងធ្វើការ ។
- ភាគីនិយោជកបានបញ្ជាក់បន្ថែមថា នៅថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០០៨ ភាគីក្រុមហ៊ុនបានជូនដំណឹងដល់កម្មករនិយោជិតទាំងអស់នៅក្នុងរោងចក្រ ស្តីអំពីរបៀបទទួលបានប្រាក់រង្វាន់ទៀងទាត់ចំនួន ៥ ដុល្លារអាមេរិក ដែលមានដូចជា:

*១. ឈប់ដោយជម្ងឺ មានលិខិតពីមន្ទីរពេទ្យពីរដ្ឋ ឬពេទ្យរោងចក្រ មួយថ្ងៃកាត់តែ ០. ១៩ ដុល្លារ ។*

*២. ឈប់សម្រាកប្រចាំឆ្នាំ ដែលបានសុំច្បាប់ជាមុន ផ្តល់ជូនទាំងស្រុង ។*

*៣. ឈប់ធម្មតាចំនួន កន្លះថ្ងៃ តែបានសុំច្បាប់ជាមុន ផ្តល់ជូនទាំងស្រុង ។*

*៤. ឈប់ធម្មតាចំនួន ១ ថ្ងៃតែបានសុំច្បាប់ជាមុន ផ្តល់ជូនតែ ៣ ដុល្លារ ។*

*៥. ឈប់អត់ច្បាប់ មិនផ្តល់ជូនឡើយ ។*

ភាគីនិយោជកបានលើកឡើងថា ភាគីកម្មករនិយោជិត ត្រូវតែអនុវត្តតាមសេចក្តីជូនដំណឹងនេះ ហើយម្យ៉ាងទៀត ប្រាក់រង្វាន់ការងារទៀងទាត់ គឺផ្តល់ជូនតែកម្មករនិយោជិតដែលបានមកធ្វើការងារទៀងទាត់ប៉ុណ្ណោះ។ ភាគីនិយោជកបានបញ្ជាក់ថា និយោជកមិនអនុញ្ញាតច្បាប់ឱ្យកម្មករនិយោជិតឈប់សម្រាកពីការងារ ក្នុងករណីដែលឡានដឹកជញ្ជូនកម្មករនិយោជិតមកធ្វើការខូចតាមផ្លូវនោះទេ។ ដូចនេះ បើកម្មករនិយោជិតអវត្តមានឥតច្បាប់ ដោយករណីឡានខូច ពួកគាត់ពុំអាចទទួលបានប្រាក់រង្វាន់ការងារទៀងទាត់នេះទេ។

- ភាគីកម្មករនិយោជិត និងនិយោជកបានឯកភាពគ្នាថា កន្លងមក នៅក្នុងខែតុលា ឆ្នាំ២០១០ ពុំមានរថយន្តខូចទេ ប៉ុន្តែ កាលពីខែកញ្ញា ឆ្នាំ២០១០ មានរថយន្តខូច ហើយកម្មករនិយោជិតអាចមកធ្វើការនៅម៉ោង ៧:១៥ នាទី ដោយក្រុមហ៊ុនរក្សាប្រាក់រង្វាន់ការងារទៀងទាត់ឱ្យនៅដដែល ។

THE ARBITRATION COUNCIL

**ចំណុចវិវាទទី៥៖ កម្មករនិយោជិតទាមទារឱ្យក្រុមហ៊ុនបើកប្រាក់ថ្លៃបាយធ្វើការបន្ថែមម៉ោង ក្នុងមួយសប្តាហ៍ម្តង**

- ភាគីនិយោជកបានលើកឡើងថា ជាទូទៅក្រុមហ៊ុនមានការងារបន្ថែមម៉ោង ឱ្យកម្មករនិយោជិតធ្វើ គឺពីថ្ងៃច័ន្ទ ដល់ថ្ងៃសុក្រ។ ការថែមម៉ោងមានរយៈពេល ២ ម៉ោង ក្នុងមួយថ្ងៃ ដោយចាប់ពីម៉ោង ១៦:០០ រហូតដល់ម៉ោង ១៨:០០ នាទីយប់ ហើយក្រុមហ៊ុនផ្តល់ប្រាក់ថ្លៃបាយសម្រាប់ការធ្វើការបន្ថែមម៉ោងនេះ ចំនួន ១៥០០ រៀល។ ក្រុមហ៊ុនបានបើកប្រាក់ថ្លៃបាយធ្វើការបន្ថែមម៉ោង ១៥០០ រៀលនេះ ជូនកម្មករនិយោជិតជាមួយនឹងប្រាក់ឈ្នួលមួយខែម្តង នៅថ្ងៃបើកប្រាក់ឈ្នួល គឺនៅថ្ងៃទី០៦ នៃខែនីមួយៗ។ ជាទូទៅ កម្មករនិយោជិតធ្វើការបន្ថែមម៉ោងតែ ២ ឬ ៣ ដង ក្នុងមួយសប្តាហ៍ទេ។ ដូចនេះ ពួកគាត់ទទួលបានតែចំនួន ៤៥០០ រៀល ប៉ុណ្ណោះ។ ភាគីកម្មករនិយោជិត ពុំបានបដិសេធទៅនឹងការលើកឡើងនេះ។
- ភាគីកម្មករនិយោជិតបានបញ្ជាក់បន្ថែមលើរយៈពេលនៃការបន្ថែមម៉ោងថា នៅក្នុងខែកញ្ញា ឆ្នាំ២០១០ មានការថែមម៉ោងច្រើន ហើយនៅក្នុងខែតុលា ឆ្នាំ២០១០ នេះ មានការថែមម៉ោងចំនួន ៨ ម៉ោង។
- ភាគីកម្មករនិយោជិតបានបញ្ជាក់ពីមូលហេតុនៃការទាមទារថា កម្មករនិយោជិតមានការខ្វះខាតប្រាក់សម្រាប់ទិញបាយហូប ពួកគាត់មិនអាចរង់ចាំរហូតដល់ថ្ងៃបើកប្រាក់ឈ្នួល នៅថ្ងៃទី០៦នៃខែនីមួយៗ បានទេ។ ដូចនេះ កម្មករនិយោជិតទាមទារឱ្យនិយោជកបើកប្រាក់ថ្លៃបាយធ្វើការបន្ថែមម៉ោងនេះម្តង ក្នុងមួយសប្តាហ៍ គឺដើម្បីឱ្យកម្មករនិយោជិត ទទួលបានប្រាក់ឆាប់យកទៅទិញបាយហូប។
- ភាគីនិយោជកបានបញ្ជាក់ថា ក្រុមហ៊ុនមិនអាចបើកជូនតាមការទាមទារទេ ព្រោះក្រុមហ៊ុនបានអនុវត្តបើកប្រាក់ថ្លៃបាយធ្វើការបន្ថែមម៉ោង ជាមួយនឹងប្រាក់ឈ្នួលមួយខែម្តងនេះ ចាប់តាំងពីក្រុមហ៊ុនបើកដំណើរការដំបូងមកម្លេះ។ ម្យ៉ាងទៀត ក្រុមហ៊ុនបានរៀបចំប្រព័ន្ធបើកប្រាក់ថ្លៃបាយនេះ តាមប្រព័ន្ធកុំព្យូទ័ររួចហើយដែរ វាពិបាកនឹងធ្វើការកែប្រែណាស់។ ទន្ទឹមនេះដែរ ក្រុមហ៊ុនមិនមានបុគ្គលិកបន្ថែមដើម្បីបើកជូនកម្មករនិយោជិតបានទេ ។
- ភាគីនិយោជកបានបញ្ជាក់ថា ប្រសិនបើមានកម្មករនិយោជិតច្រើនទាមទារ ក្រុមហ៊ុននឹងពិចារណា ពីព្រោះមុននឹងមកចូលរួមសវនាការនេះ ក្រុមហ៊ុនបានធ្វើការស្ទង់មតិលើកម្មករនិយោជិតមួយចំនួន ហើយជាលទ្ធផលពិនិត្យឃើញថា មិនមានកម្មករនិយោជិតភាគច្រើនដែលទាមទារឱ្យក្រុមហ៊ុន បើកប្រាក់ថ្លៃបាយធ្វើការបន្ថែមម៉ោងមួយសប្តាហ៍ម្តងនេះទេ។ ប៉ុន្តែ ភាគីកម្មករនិយោជិតបានជំទាស់ទៅនឹងការលើកឡើងនេះ ដោយបញ្ជាក់ថា មានកម្មករនិយោជិតភាគច្រើនដែលបានធ្វើទាមទារ ។
- ភាគីកម្មករនិយោជិតបញ្ជាក់ជំហរថា កម្មករនិយោជិតនៅតែទាមទារឱ្យក្រុមហ៊ុន បើកប្រាក់ថ្លៃបាយធ្វើការបន្ថែមម៉ោង មួយសប្តាហ៍ម្តង ដដែល។

THE ARBITRATION COUNCIL

**ហេតុផលនៃសេចក្តីសម្រេចៈ**

**ចំណុចវិវាទទី១: កម្មករនិយោជិតនៅតែទាមទារឱ្យក្រុមហ៊ុនរក្សាប្រាក់ឈ្នួល និងប្រាក់រង្វាន់ដដែល នៅពេលរថយន្តខូចតាមផ្លូវ**

ក្នុងករណីនេះ ភាគីកម្មករនិយោជិត បានដកចំណុចទាមទារទៅលើការសុំរក្សាប្រាក់ឈ្នួល ប៉ុន្តែ រក្សាការទាមទារសុំកុំឱ្យនិយោជកកាត់ប្រាក់រង្វាន់ការងារទៀងទាត់ បើសិនជាកម្មករនិយោជិតមិនបានមកធ្វើការដោយសារតែរថយន្តជូនពួកគាត់មកធ្វើការខូចនៅតាមផ្លូវ។ ក្នុងករណីនេះ និយោជកបានកាត់ប្រាក់រង្វាន់ការងារទៀងទាត់ចំនួន ៥ ដុល្លារអាមេរិក ទាំងអស់តែម្តង។ ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណាថា តើនិយោជកត្រូវរក្សាប្រាក់រង្វាន់ការងារទៀងទាត់ទាំងអស់ជូនកម្មករនិយោជិត ដែរ ឬទេ ក្នុងករណីដែលកម្មករនិយោជិតមិនបានមកធ្វើការដោយសារតែរថយន្តខូចនៅតាមផ្លូវ ?

ចំណុចទី៣ នៃសេចក្តីជូនដំណឹងលេខ ៧៤៥ កកបវ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០០៦ ចែងថា *"អត្ថប្រយោជន៍នានា ដែលកម្មករនិយោជិតធ្លាប់ទទួលតាមសេចក្តីជូនដំណឹងលេខ ០១៧ សកបយ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០០ ត្រង់ចំណុចទី៣ ទី៤ ទី៥ និង ទី៦ ត្រូវរក្សាទុកដដែល។"*

ចំណុចទី៣ នៃសេចក្តីជូនដំណឹងលេខ ០១៧ សកបយ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០០ ចែងថា *"កម្មករនិយោជិតដែលធ្វើការទៀតទាត់នៃចំនួនថ្ងៃដែលត្រូវធ្វើការក្នុងមួយខែៗនោះ ត្រូវបានប្រាក់រង្វាន់យ៉ាងតិចចំនួន ៥ ដុល្លារអាមេរិកក្នុងមួយខែ។"*

ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងមុនៗ យល់ឃើញថា ប្រាក់រង្វាន់ការងារទៀងទាត់ចំនួន ៥ ដុល្លារអាមេរិក ចែងក្នុងសេចក្តីជូនដំណឹងលេខ ០១៧ សកបយ នេះ មានន័យថា ជាប្រាក់រង្វាន់សម្រាប់លើកទឹកចិត្តដល់កម្មករនិយោជិតដែលធ្វើការមួយខែពេញ ដោយមិនមានឈប់ដោយគ្មានការអនុញ្ញាត (អវត្តមានគ្មានច្បាប់) នោះទេ។ ( *សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាល លេខ ១៤៣/០៨-ឆាម ចិចថាយ ហេតុផលនៃចំណុចវិវាទទី៧ និង១៥២/០៨-វីលសិន ហេតុផលនៃចំណុចវិវាទទី១* )។

លើសពីនេះទៅទៀត នៅក្នុងសំណុំរឿងមុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបង្គាប់ឱ្យនិយោជកកាត់ប្រាក់រង្វាន់ការងារទៀងទាត់ សមាមាត្រទៅតាមថ្ងៃ ដែលកម្មករនិយោជិតអវត្តមានដោយមានការអនុញ្ញាតពីនិយោជកឱ្យឈប់សម្រាក។ (*សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាល លេខ ៥៧/០៧-ស៊ីរ៉ាតិច ហេតុផល ចំណុចវិវាទទី៣ និងលេខ ១៤៣/០៨-ឆាម ចិចថាយ ហេតុផលនៃចំណុចវិវាទទី៧*)។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា បើកម្មករនិយោជិតអវត្តមាននៅថ្ងៃណាមួយ ដោយគ្មានច្បាប់អនុញ្ញាតពីនិយោជក មានន័យថា កម្មករនិយោជិតមិនបានមកធ្វើការទៀងទាត់ស្របតាមសេចក្តីជូនដំណឹងលេខ ០១៧ សកបយ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០០ ឡើយ។ ហេតុនេះ កម្មករនិយោជិតមិនមានសិទ្ធិទទួលបានប្រាក់រង្វាន់ធ្វើការទៀតទាត់ចំនួន ៥ ដុល្លារអាមេរិក នេះទេ។ នៅក្នុងសំណុំរឿងមុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ARBITRATION COUNCIL

បានបកស្រាយថា និយោជកមានសិទ្ធិកាត់ប្រាក់រង្វាន់ការងារទៀងទាត់ទាំងអស់ នៅពេលកម្មករនិយោជិតអវត្តមានដោយគ្មានការអនុញ្ញាតពីនិយោជក។ *(សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាល លេខ ៧០/០៧-អិល អេហ្គាមិន ហេតុផលនៃចំណុចវិវាទទី៤. លេខ៥៣/០៩-តាក ហ្វាត ហេតុផលនៃចំណុចវិវាទទី១ និងលេខ ១៥២/០៨-វីលសិន ហេតុផលនៃចំណុចវិវាទទី១)*។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងនេះ ក៏យល់ស្របនឹងការបកស្រាយរបស់អាជ្ញាកណ្តាលនៅក្នុងសំណុំរឿងមុនៗដែរ គឺកម្មករនិយោជិតមានសិទ្ធិទទួលបានប្រាក់រង្វាន់ធ្វើការទៀងទាត់ សមាមាត្រទៅតាមថ្ងៃដែលកម្មករនិយោជិតអវត្តមាន ដោយមានការអនុញ្ញាតពីនិយោជកឱ្យឈប់សម្រាកតែប៉ុណ្ណោះ។

តាមរយៈអង្គហេតុ និងសេចក្តីជូនដំណឹង ស្តីអំពីរបៀបទទួលបានប្រាក់រង្វាន់ការងារទៀងទាត់ចំនួន ៥ ដុល្លារអាមេរិក និយោជកពុំបានអនុញ្ញាតឱ្យកម្មករនិយោជិតឈប់សម្រាកទេ នៅពេលដែលកម្មករនិយោជិតឈប់ ឬអវត្តមាន ដោយសារតែរថយន្តខូចនៅតាមផ្លូវ។ ពោលគឺ និយោជកធ្វើការកាត់ប្រាក់រង្វាន់ការងារទៀងទាត់នេះទាំងអស់នៅក្នុងករណីនេះ។ ផ្អែកតាមសេចក្តីជូនដំណឹងរបស់ភាគីនិយោជក និងយុត្តិសាស្ត្ររបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា កម្មករនិយោជិតពុំអាចទទួលបានប្រាក់រង្វាន់ទៀងទាត់ចំនួន ៥ ដុល្លារអាមេរិក នេះទេ។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេច បដិសេធការទាមទាររបស់កម្មករនិយោជិត ឱ្យនិយោជកផ្តល់ប្រាក់រង្វាន់ធ្វើការងារទៀងទាត់ចំនួន ៥ ដុល្លារអាមេរិក នៅពេលដែលពួកគាត់ឈប់សម្រាកដោយគ្មានការអនុញ្ញាតដោយមូលហេតុរថយន្តខូច។

**ចំណុចវិវាទទី៥ : កម្មករនិយោជិតទាមទារឱ្យក្រុមហ៊ុនបើកប្រាក់ថ្លៃបាយធ្វើការបន្ថែមម៉ោង ក្នុងមួយសប្តាហ៍ម្តង**

ក្នុងករណីនេះ ក្រុមហ៊ុនបានអនុវត្តបើកប្រាក់ថ្លៃបាយធ្វើការបន្ថែមម៉ោងជាមួយនឹងប្រាក់ឈ្នួលមួយខែម្តង។ ប៉ុន្តែ កម្មករនិយោជិតទាមទារឱ្យក្រុមហ៊ុនបើកប្រាក់ថ្លៃបាយធ្វើការបន្ថែមម៉ោង មួយសប្តាហ៍ម្តង ពីព្រោះ កម្មករនិយោជិតមានការខ្វះខាតប្រាក់សម្រាប់ទិញបាយហូប ដោយមិនអាចរង់ចាំរហូតដល់ថ្ងៃបើកប្រាក់ឈ្នួលប្រចាំខែនោះទេ។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណាថា តើកម្មករនិយោជិតមានសិទ្ធិអាចទាមទារឱ្យក្រុមហ៊ុនបើកប្រាក់ថ្លៃបាយធ្វើការបន្ថែមម៉ោង មួយសប្តាហ៍ម្តងបានដែរ ឬទេ តាមច្បាប់ស្តីពីការងារ?

មាត្រា ១១៦ នៃច្បាប់ពីការងារបានចែងថា *" ប្រាក់ឈ្នួលនៃកម្មករ ត្រូវបើកយ៉ាងហោចណាស់ពីរដងក្នុងមួយខែ ដោយមានចន្លោះពេលយ៉ាងច្រើនដប់ប្រាំមួយថ្ងៃ។ ប្រាក់ឈ្នួលនៃនិយោជិតត្រូវបើកយ៉ាងហោចណាស់មួយដងក្នុងមួយខែ។......"*

ផ្អែកលើមាត្រាខាងលើនេះ ក្រុមប្រឹក្សាកណ្ដាលយល់ឃើញថា **ប្រាក់ឈ្នួលនៃកម្មករ** ត្រូវបើកយ៉ាងហោចណាស់ពីរដងក្នុងមួយខែ ចំណែកឯ**ប្រាក់ឈ្នួលនៃនិយោជិត** ត្រូវបើកយ៉ាងហោចណាស់ មួយដងក្នុងមួយខែ។ ច្បាប់ស្ដីពីការងារបានកំណត់តែពេលវេលានៃការបើកប្រាក់ឈ្នួលតែប៉ុណ្ណោះ។

ប៉ុន្តែ ក្នុងករណីនេះ កម្មករនិយោជិតបានទាមទារឱ្យក្រុមហ៊ុនបើកប្រាក់ថ្លៃបាយធ្វើការបន្ថែមម៉ោង មួយសប្ដាហ៍ម្ដង។ ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាល នឹងពិចារណាថា តើប្រាក់ថ្លៃបាយធ្វើការបន្ថែមម៉ោង ជាប្រាក់ឈ្នួលដែរ ឬទេ ហើយកម្មករនិយោជិតអាចបើកប្រាក់ថ្លៃបាយធ្វើការបន្ថែមម៉ោងមួយសប្ដាហ៍ម្ដង ឬទេ?

មាត្រា១០៣ នៃច្បាប់ស្ដីពីការងារចែងថា *"ប្រាក់ឈ្នួលមានជាអាទិ៍ដូចតទៅ :*

- *ប្រាក់ឈ្នួលសុទ្ធសាធ*
- *ប្រាក់ម៉ោងបន្ថែម*
- *... "*។

តាមខ្លឹមសារមាត្រា ១០៣ កថាខណ្ឌទី១ ចំណុចទី២ នៃច្បាប់ស្ដីពីការងារខាងលើ ប្រាក់ម៉ោងបន្ថែមជាផ្នែកមួយនៃប្រាក់ឈ្នួល។ ជាមួយគ្នានេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលយល់ឃើញថា កម្មករនិយោជិតអាចទទួលបានប្រាក់ថ្លៃបាយធ្វើការបន្ថែមម៉ោង តែក្នុងករណីដែលកម្មករនិយោជិតធ្វើការងារបន្ថែមម៉ោងប៉ុណ្ណោះ។ ប្រាក់ថ្លៃបាយធ្វើការបន្ថែមម៉ោងនេះ មានទំនាក់ទំនងជាមួយប្រាក់ម៉ោងបន្ថែម។ ដូចនេះ សំណួរសួរថា តើប្រាក់ថ្លៃបាយធ្វើការបន្ថែមម៉ោង អាចជាផ្នែកនៃប្រាក់ម៉ោងបន្ថែមដែរ ឬទេ ហើយនឹងអាចបើកជាមួយប្រាក់ឈ្នួលដែរ ឬទេ?

ចំណុចទី៣ នៃសេចក្ដីជូនដំណឹងលេខ ៧៤៥ ក.ក.ប.វ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០០៦ ក៏បានចែងដែរថា *"អត្ថប្រយោជន៍នានាផ្សេងទៀត ដែលកម្មករនិយោជិតធ្លាប់បានទទួលតាមសេចក្ដីជូនដំណឹងលេខ ០១៧ សកបយ. ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០០ ត្រង់ចំណុចទី៣ ទី៤ ទី៥ និងទី៦ ត្រូវរក្សាទុកដដែល"*។

ចំណុចទី៤ នៃសេចក្ដីជូនដំណឹងលេខ ០១៧ សកបយ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០០ ចែងថា *"កម្មករនិយោជិតដែលស្ម័គ្រចិត្តធ្វើការបន្ថែមម៉ោងតាមសំណូមពររបស់និយោជកត្រូវទទួលបានប្រាក់ថ្លៃបាយចំនួន ១០០០ រៀល ក្នុងមួយថ្ងៃ ឬទទួលបានការផ្ដល់ជូនបាយមួយពេល ដោយឥតគិតថ្លៃ ។"*

ក្នុងសំណុំរឿងមុនក្រុមប្រឹក្សាអាជ្ញាកណ្ដាលយល់ឃើញថា ប្រាក់ថ្លៃបាយធ្វើការបន្ថែមម៉ោង មិនមែនជាផ្នែកនៃប្រាក់ម៉ោងបន្ថែមទេ ពីព្រោះប្រាក់នេះ ជាប្រាក់ជំនួសថ្លៃបាយ វាមិនមែនជាកម្រៃ ដែលបានមកពីការងារបន្ថែមម៉ោងទេ។ ប្រសិនបើនិយោជកមិនផ្ដល់ប្រាក់ថ្លៃបាយនេះទេ និយោជកមានកាតព្វកិច្ចត្រូវផ្ដល់បាយមួយពេលដោយឥតគិតថ្លៃដែរ។ ដូច្នេះ ការផ្ដល់ប្រាក់ថ្លៃបាយធ្វើការបន្ថែមម៉ោង មិនមានទំនាក់ទំនងជាមួយនឹងការផ្ដល់ប្រាក់ឈ្នួលម៉ោងបន្ថែមពេលធ្វើការងារបន្ថែមម៉ោងនោះទេ។ *(សូមមើលសេចក្ដីបង្គាប់អាជ្ញាកណ្ដាលលេខ ១១០/០៩- ប៊ី រី អឹកែរឹល ហេតុផលចំណុចវិវាទទី១)* ។

THE ARBITRATION COUNCIL

នៅក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាល ក៏យល់ស្របទៅតាមការបកស្រាយរបស់ក្រុមប្រឹក្សាអាជ្ញាកណ្ដាលខាងលើដែរ ពោលគឺ ការផ្ដល់ប្រាក់ថ្លៃបាយធ្វើការបន្ថែមម៉ោង ពុំមានទំនាក់ទំនងជាមួយការផ្ដល់ប្រាក់ឈ្នួលម៉ោងបន្ថែម ពេលធ្វើការងារបន្ថែមម៉ោងនោះទេ។ ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលយល់ឃើញថា ប្រាក់ថ្លៃបាយបន្ថែមម៉ោងអាចបើកផ្សេងគ្នា ពីប្រាក់ឈ្នួលរបស់កម្មករនិយោជិតបាន។

យោងតាមសេចក្ដីជូនដំណឹងលេខ ០១៧ សកបយ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០០ ខាងលើ នៅពេលដែលកម្មករនិយោជិតស្ម័គ្រចិត្តធ្វើការងារបន្ថែមម៉ោង ពួកគាត់នឹងត្រូវទទួលបានប្រាក់ថ្លៃបាយចំនួន ១០០០ រៀល ឬទទួលបានការផ្ដល់ជូនបាយមួយពេលដោយឥតថ្លៃ។ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលយល់ឃើញថា ការផ្ដល់បាយមួយពេលនេះ គឺជាការផ្ដល់កម្លាំងបន្ថែមទៀត ដើម្បីធ្វើការបន្ថែមម៉ោងបន្ទាប់ពីចប់ម៉ោងធ្វើការធម្មតា ដែលត្រូវបន្តទៅម៉ោងខាងមុខទៀតព្រោះថា បាយ គឺជាតម្រូវការចាំបាច់ប្រចាំថ្ងៃរបស់មនុស្សគ្រប់រូប ដែលមិនអាចអត់បាន ហើយដែលនិយោជកត្រូវតែផ្ដល់ឱ្យ។ យ៉ាងណាមិញ ទោះបីជានិយោជកមិនអាចផ្ដល់បាយឱ្យកម្មករនិយោជិតនៅពេលធ្វើការថែមម៉ោង ក៏សេចក្ដីជូនដំណឹងលេខ ០១៧ សកបយ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០០ បានកំណត់ឱ្យនិយោជកផ្ដល់ប្រាក់ថ្លៃបាយជំនួសការផ្ដល់បាយដោយឥតគិតថ្លៃដែរ។ ប៉ុន្តែ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលយល់ឃើញថា សេចក្ដីជូនដំណឹងនេះ ក៏មិនបានបញ្ជាក់អំពីពេលវេលានៃការបើកប្រាក់ថ្លៃបាយធ្វើការបន្ថែមម៉ោងដែរ។

នៅក្នុងសេចក្ដីបង្គាប់របស់ក្រុមប្រឹក្សាអាជ្ញាកណ្ដាល លេខ ១១០/០៩-ប៊ី វី អឹភែវីល ហេតុផលចំណុចវិវាទទី១ បានបកស្រាយថា "*ការបើកប្រាក់ថ្លៃបាយធ្វើការបន្ថែមម៉ោងដល់កម្មករនិយោជិត ត្រូវធ្វើឡើងក្នុងរយៈពេលមួយសមស្របដែលត្រូវធានាថា កម្មករនិយោជិតអាចមានប្រាក់ទិញបាយសម្រាប់ហូបពេល ធ្វើការបន្ថែមម៉ោង មិនថាការបើកប្រាក់ថ្លៃបាយធ្វើការបន្ថែមម៉ោងធ្វើឡើងជារៀងរាល់ថ្ងៃ ឬជារៀងរាល់សប្ដាហ៍ ឬជារៀងរាល់ខែនោះទេឱ្យតែកម្មករនិយោជិតអាចចាត់ចែងប្រាក់នោះសម្រាប់ទិញបាយហូបពេលធ្វើការបន្ថែមម៉ោងបាន*"

យោងតាមការបកស្រាយខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលយល់ឃើញថា គោលបំណងចម្បងរបស់សេចក្ដីជូនដំណឹងលេខ ០១៧ សកបយ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០០ គឺធានាថា កម្មករនិយោជិតអាចមានបាយមួយពេលសម្រាប់ហូបពេលធ្វើការបន្ថែមម៉ោង ដោយមិនគិតថា និយោជកផ្ដល់ជាបាយមួយពេលដោយឥតគិតថ្លៃ ឬក៏ផ្ដល់ជាប្រាក់ថ្លៃបាយធ្វើការបន្ថែមម៉ោងចំនួន ១០០០ រៀលក្នុងមួយថ្ងៃនោះទេ។

យោងតាមអង្គហេតុជាក់ស្ដែងនៅក្នុងសំណុំរឿងនេះ កម្មករនិយោជិតទាមទារឱ្យនិយោជកបើកប្រាក់ថ្លៃបាយបន្ថែមម៉ោងរៀងរាល់មួយសប្ដាហ៍ម្ដង ដោយហេតុថា គាត់ត្រូវការប្រាក់នេះ ដើម្បីចាត់ចែងទិញបាយហូបពេលធ្វើការបន្ថែមម៉ោង ដោយសារតែកម្មករនិយោជិតមានការខ្វះខាតប្រាក់សម្រាប់ទិញបាយហូប ដោយមិនអាចរង់ចាំរហូតដល់ថ្ងៃបើកប្រាក់ឈ្នួល។ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលយល់ឃើញថា កម្មករនិយោជិតមានហេតុផលសមស្របក្នុងការទាមទារឱ្យនិយោជកបើកប្រាក់ថ្លៃបាយបន្ថែមម៉ោងរៀងរាល់មួយសប្ដាហ៍ម្ដង ដើម្បីចាត់ចែងយកទៅទិញបាយហូបពេលធ្វើការបន្ថែមម៉ោង។ ចំពោះហេតុផលរបស់និយោជក ដែលពិបាកផ្លាស់ប្ដូរប្រព័ន្ធគណនេយ្យ

ក្នុងការបើកប្រាក់ថ្លៃបាយបន្ថែមម៉ោងនោះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា និយោជកអាចរិះរកមធ្យោបាយផ្សេងៗ ដើម្បីរៀបចំបើកជូនកម្មករនិយោជិត ព្រោះថា ប្រាក់ថ្លៃបាយបន្ថែមម៉ោង ចំពោះកម្មករនិយោជិតវាមានសារៈសំខាន់ណាស់។ បញ្ហាខ្វះខាតដែលជាតម្រូវការក្រពះរបស់កម្មករនិយោជិត ពិបាកដោះស្រាយណាស់ ប្រសិនបើនិយោជកមិនបើកប្រាក់ថ្លៃបាយបន្ថែមម៉ោង ជូនពួកគាត់រៀងរាល់មួយសប្តាហ៍ម្តងនោះ។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាល បង្គាប់ឱ្យនិយោជកបើកប្រាក់ថ្លៃបាយធ្វើការបន្ថែមម៉ោង មួយសប្តាហ៍ម្តង ជូនកម្មករនិយោជិតដែលធ្វើការបន្ថែមម៉ោង។

យោងតាមអង្គហេតុ ដែលបានរកឃើញ អង្គច្បាប់ និងហេតុផលដូចបានពន្យល់ខាងដើម ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេច ដូចតទៅនេះ:

## សម្រេច និង បង្គាប់

**ចំណុចវិវាទទី១ :** បដិសេធការទាមទាររបស់កម្មករនិយោជិត ឱ្យនិយោជកផ្តល់ប្រាក់រង្វាន់ធ្វើការងារទៀងទាត់ចំនួន ៥ ដុល្លារអាមេរិក នៅពេលដែលពួកគាត់ឈប់សម្រាក ដោយគ្មានការអនុញ្ញាត ដោយមូលហេតុរថយន្តខូច។

**ចំណុចវិវាទទី៥ :** បង្គាប់ឱ្យនិយោជកបើកប្រាក់ថ្លៃបាយធ្វើការបន្ថែមម៉ោង មួយសប្តាហ៍ម្តង ជូនកម្មករនិយោជិតដែលធ្វើការបន្ថែមម៉ោង។

**ប្រភេទនៃសេចក្តីបង្គាប់ : សេចក្តីបង្គាប់មិនជាប់កាតព្វកិច្ច**

*សេចក្តីបង្គាប់នេះនឹងក្លាយជាស្ថាពរ បន្ទាប់ពីថ្ងៃជូនដំណឹងអំពីសេចក្តីបង្គាប់ចំនួន០៨ថ្ងៃ បើសិនជាមិនមានភាគីណាមួយដាក់ពាក្យជំទាស់ជាលាយលក្ខណ៍អក្សរទៅរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈតាមរយៈលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងរយៈពេលនេះទេ។*

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្តាល**

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក :

ឈ្មោះ : **ម៉ារ សំបូរណា**

ហត្ថលេខា: ------------------------------

THE ARBITRATION COUNCIL

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិត :

ឈ្មោះ : **អាន វីរះ**

ហត្ថលេខា: ------------------------------------

ប្រធានក្រុមអាជ្ញាកណ្តាល :

ឈ្មោះ : **ម៉ែន ម៉ុនឈយា**

ហត្ថលេខា: ------------------------------------